វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (អនុវត្តន៍សំណង់ស៊ីវិល)

សំណួរទី 1
ម៉ាស៊ីនដែលជាអេស្កាវ៉ាទ័រអ៊ីដ្រូលីកមួយ ហើយនៅខាងចុងនៃដៃមានភ្ជាប់ប៉ែល តើហៅថាអ្វី?

1. អេស្កាវ៉ាទ័រ (Power shovel)
2. ប៊ុលដូហ្ស៊ែរ
3. រ៉ូឡូកិន
4. រ៉ូឡូកិនថ្នល់

ចម្លើយៈ 1

សំណួរទី 2
តើប្រអប់ធ្វើពីបេតុងសរសៃដែកដែលត្រូវបានប្រើពេលសាងសង់ទំនប់ការពាររលកឬផែ គឺហៅថាអ្វី?

1. ដុំបេតុងបំបាត់រលក
2. កេះសុង (caisson)
3. យុថ្កា
4. ប៉ែលចាប់

ចម្លើយៈ 2

សំណួរទី 3
តើប្រភេទនៃរន្ទាដែលផ្គុំដំឡើងសម្ភារមូលដ្ឋានដូចជា ជើងសារ៉េ ដែកខ្វែង បន្ទះក្រាល មានតម្លក់ធ្វើពីដែកជាដើម ដោយយកគ្រោងដែករាងជាខ្លោងទ្វារជាគោល គឺហៅថាអ្វី?

1. រន្ទាថ្នក់កង(ringlock)
2. រន្ទាបំពង់ទីប
3. រន្ទាគ្រោងដែក
4. បន្ទះក្រាល

ចម្លើយ៖ 3

## វិញ្ញាសាគំរូ  ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (អនុវត្តន៍សំណង់ស៊ីវិល)

សំណួរទី 4
តើឧបករណ៍ ប៉ែលក្បាលស្រួច(កេនទ ស៊ុកុបពុ) សម្រាប់ជីកដីដោយដាក់ជើងលើផ្នែកខាងលើនៃក្បាលប៉ែល គឺមួយណា?

1.
2.
3.
4.




ចម្លើយៈ 1

សំណួរទី 5
តើម៉ាស៊ីនក្នុងរូបថតមានឈ្មោះអ្វី?

1. ម៉ាស៊ីនវាយកូរ
2. កញ្ច្រែង
3. ម៉ែត្ររុំ
4. ម៉ាស៊ីនលាយបេតុង



ចម្លើយ៖ 4

សំណួរទី 6
ក្នុងការងារជីកផ្លូវរូងរុញទៅមុខ តើរបស់ដែលគេសាងសង់នៅខាងចំណុចចាប់ផ្តើមនៃការងារសាងសង់ សម្រាប់ជាទីមូលដ្ឋានផ្លូវរូងនិងជាផ្នែកទំនាក់ទំនងជាមួយផ្នែកផ្ទៃដីខាងលើ គឺមួយណា?

1. រូងជីករ៉ែ
2. រូងរុញទៅមុខ
3. រណ្តៅ
4. រូង

ចម្លើយ៖ 3

សំណួរទី 7
តើការសាងសង់បំពង់ស្រូបទឹក well point គឺជាការងារមួយណា?

1. ការងារធ្វើឲ្យកម្រិតទឹកនៃទឹកក្រោមដី មានកម្រិតទាប
2. ការងារធ្វើឲ្យទឹកទន្លេស្អាត
3. ការងារធ្វើឲ្យដីស្អាត
4. ការងារយកចេញដីខ្សាច់

ចម្លើយ៖ 1

សំណួរទី 8
ក្នុងការងារខ្វងអណ្តូង តើការបញ្ជូនចរន្តអគ្គិសនីចូលទៅក្នុងរណ្តៅដើម្បីពិនិត្យថាសមស្របជាស្រទាប់យកទឹកដែរឬអត់គឺហៅថាអ្វី?

1. ការពិនិត្យស្រទាប់ដីដោយអគ្គិសនី
2. រ៉េស៊ីស្តង់អគ្គិសនី
3. ទូរគមនាគមន៍
4. ការពិនិត្យការលេចធ្លាយអគ្គិសនី

ចម្លើយៈ 1

សំណួរទី 9
ក្នុងរចនាសម្ព័ន្ធផ្លូវថ្នល់ក្រាលកម្រាល តើផ្នែកខាងក្រោមកម្រាលផ្លូវថ្នល់ហៅថាអ្វី?

1. ស្រទាប់ផ្ទៃខាងលើកម្រាលថ្នល់
2. ស្រទាប់ទ្រនាប់កម្រាលថ្នល់
3. គ្រឹះថ្នល់
4. ស្រទាប់ដីសម្រាំង

ចម្លើយ ៖ 4

សំណួរទី 10
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។

ក្នុងចំណោមគ្រោះថ្នាក់ក្នុងការងារសំណង់ស៊ីវិល គ្រោះថ្នាក់ដែលមានច្រើនគឺ "ធ្លាក់/រអិលធ្លាក់" "(          )" "គាបជាប់/ការរមួលចូល"។

1. ខ្ទាត/ធ្លាក់ត្រូវ
2. បុកប៉ះ
3. បាក់រលំ/ដួលរលំ

ចម្លើយ៖ 3

សំណួរទី 11
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(　　　) ក្នុងប្រយោគខាងក្រោម។ តើគ្រោះ

ថ្នាក់ការងារដែលបណ្តាលមកពីការធ្លាក់ពីកន្លែងខ្ពស់ ការធ្លាក់តាមលំហរវាងជាន់នីមួយៗ ពេលកំពុងសាងសង់ ឬប្រហោងជាដើមពេលកំពុងជីក គឺមួយណា?

1. ធ្លាក់/រអិលធ្លាក់
2. ដួល
3. បុកប៉ះ

ចម្លើយៈ 1

សំណួរទី 12
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(           ) ក្នុងប្រយោគខាងក្រោម។

ការធ្លាក់គឺកើតមានច្រើនដោយសារការបាត់លំនឹង ការរអិលជើងជាដើម ដូច្នេះនៅទីខ្ពស់ត្រូវពាក់(           )ឲ្យបានប្រាកដ។

1. ស្រោមដៃសម្រាប់ការងារ
2. ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយ

ចម្លើយៈ 2

សំណួរទី 13
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។

គ្រោះថ្នាក់ស្លាប់នៅការដ្ឋានសំណង់ស្ទើរពាក់កណ្តាលគឺកើតឡើង(          )ក្រោយពីចូលការដ្ឋានថ្មី។

1. ក្នុងរង្វង់ 1 ថ្ងៃ
2. ក្នុងរង្វង់ 1 សប្តាហ៍
3. ក្នុងរង្វង់ 1 ខែ

ចម្លើយៈ 2

សំណួរទី 14
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។

តើកន្លែងដែលត្រូវសម្រាកនៅម៉ោងសម្រាកដែលបានកំណត់ក្នុងនាមជាវិធានការការពារជំងឺស្រ្តូកកម្ដៅ គឺមួយណា?

1. កន្លែងត្រូវពន្លឺព្រះអាទិត្យ
2. កន្លែងក្ដៅ
3. កន្លែងត្រជាក់

ចម្លើយ៖ 3